ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១២៩/១១-អិម វ៉េ (សាខាកំពង់ឆ្នាំង)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ ម៉ារ សំបូរណា
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ ទូន ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ ប៉ែន ប៊ុនឈា

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **អិម វ៉េ កាត់ដេរ អន្តរជាតិ លីមីធីត (សាខាកំពង់ឆ្នាំង)**
អាសយដ្ឋាន ៖ ភូមិត្រពាំងចឹក្សា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០១៦ ៧០៧ ០៤៦ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក ឃិន ណាក់ | តំណាងក្រុមហ៊ុន អិម វ៉េ |
| ២- លោក ស៊ុន វណ្ណៈ | រដ្ឋបាល |
| ៣- លោក អ៊ុន ឆន្ទៈ | ជំនួយការនាយក |
| ៤- លោក ហំ ភា | មេធាវី |
| ៥- លោក វីម វីរៈ | ជំនួយការមេធាវី |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖- **សហជីពសេរីកម្មករនៃក្រុមហ៊ុន តម្បាញ អ៊ីម និង វ៉េ កំពង់ឆ្នាំង**
- **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

អាសយដ្ឋាន ៖ ភូមិត្រពាំងចក្រា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០១២ ៩៣៥ ៤៩៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតៈ

| | |
|---|---|
| ១- លោក ម៉ាន់ សេងហាក់ | មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា |
| ២- លោក ខឹម ចំណាន | មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា |
| ៣- លោកស្រី ទឹម ស៊ីឡាត់ | ប្រធានសហជីពសេរីកម្មករនៃក្រុមហ៊ុន អ៊ុំ និង វេ |
| ៤- លោកស្រី មាស សុខេន | អនុប្រធានសហជីព |
| ៥- កញ្ញា ផៃ សុផារី | កម្មករ |
| ៦- កញ្ញា ឃុត ស្រីល័ក្ខណ៍ | កម្មករ |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ទាមទារឱ្យនាយក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីព រួមទាំងសកម្មជនមួយចំនួនទៀតដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១។

២- ទាមទារឱ្យក្រុមហ៊ុនរៀបចំឱ្យមានថ្នាំពេទ្យគ្រប់គ្រាន់ និងគ្រូពេទ្យប្រចាំការចំពោះកម្មករ កម្មការិនី វេនយប់ ។

៣- ទាមទារឱ្យក្រុមហ៊ុនរៀបចំកន្លែងសំរាកញ៉ាំបាយចំពោះកម្មករ កម្មការិនី វេនយប់ ។

៤- ចំពោះកម្មករ កម្មការិនី វេនយប់ ឈឺ ឬសន្លប់ ក្រុមហ៊ុនដេញឱ្យទៅផ្ទះទាំងយប់ មិនគិតពីសុវត្ថិភាពឡើយ ។

៥- កម្មករ កម្មការិនីធ្វើការមួយខែ ស្មើរនឹង ៣០ ថ្ងៃ មិនគិតថ្ងៃបុណ្យ និងថ្ងៃអាទិត្យឡើយ ។

៦- បើកម្មករ កម្មការិនីណាមិនមកធ្វើការថ្ងៃបុណ្យ ឬថ្ងៃអាទិត្យ ត្រូវតែដាច់ប្រាក់រង្វាន់ និងប្រាក់ប្រចាំថ្ងៃ

៧- ចំពោះអាគារស្វ័យប្រវត្តិកុំព្យូទ័រ មានកម្មករ ៤០០ នាក់ ធ្វើការកន្លះខែយប់ កន្លះខែថ្ងៃ មានការតៀបសង្កត់ខ្លាំងណាស់ ។

៨- ពិបាកក្នុងការសុំច្បាប់មានចុះៈចាំបាច់ម្តងម្កាល ដូចជាឪពុកម្តាយឈឺ (ផ្ញើរកាតមកសុំច្បាប់មិនអនុញ្ញាតទេ) ពេលចូលធ្វើការវិញ ក្រុមហ៊ុនបញ្ឈប់ ឬបង្ខំឱ្យដាក់លិខិតលាលែងដោយខ្លួនឯង ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ

០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥៩៣១ កប/កនរ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានទទួលលិខិតស្តីពីការជូនដំណឹងអំពីការធ្វើកូដកម្ម ដើម្បីទាមទារលក្ខខណ្ឌការងារមួយចំនួន របស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ៣៨៥/១១ សសកពក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក មន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ ជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៨ ចំណុច លើការទាមទារចំនួន ០៨ ចំណុច។ ចំណុចមិនសះជាចំនួន ០៨ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ៥៩៣ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៨ ចំណុចនេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៨ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៧ ចំណុច គឺចំណុចវិវាទទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ និងមិនសះជាចំនួន ០១ ចំណុច គឺចំណុចវិវាទទី១។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុង

សំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេចដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។ ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីប្រយោជន៍។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែក លើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោមៈ

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- សារណានៃសំណុំរឿងវិវាទការងាររួមលេខ ១២៩/១១ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ។

២- ពាក្យសុំរក្សាការពាររបស់នាយកក្រុមហ៊ុន អឹម វ៉េ សាខាទី៤ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ។

៣- ដីការសំរេចរក្សាការពាររបស់សាលាដំបូងខេត្តកំពង់ឆ្នាំង លេខ ៥៨ (ក) ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១១ ។

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន អឹម វ៉េ សាខាកំពង់ឆ្នាំង ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ ២០១១ ។

៥- លិខិតជូនដំណឹងធ្វើកូដកម្មរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ៣៨៥/១១ សសកពក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន អឹម វ៉េ កំពង់ឆ្នាំង ។

៦- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ មាស សុខេន ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ។

៧- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន មាស សុខេន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

៨- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ មាស សុខេន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

៩- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ។

១០- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ទឹម ស៊ីឡាត់ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

១១- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

១២- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាលេខ ៣៦៩/១១ សសកពក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន អ៊ឹម វ៉េ កំពង់ឆ្នាំង ស្តីពីការជូនដំណឹងអំពីមេដឹកនាំជាប់ឆ្នោតសហជីពសេរីកម្មករនៃរោងចក្រតម្បាញ អ៊ឹម វ៉េ កំពង់ឆ្នាំង ។

១៣- កំណត់ហេតុផ្តាច់កិច្ចសន្យា ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

១៤- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់នាយកក្រុមហ៊ុន អិម វ៉េ កាត់ដេរអន្តរជាតិ លីមីធីត ជូនលោកមេធាវី ហំ ភា ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ។

១៥- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់នាយកក្រុមហ៊ុន អិម វ៉េ កាត់ដេរអន្តរជាតិ លីមីធីត ជូនលោក យិន ណាក់, អ៊ុន ឆន្ទះ, និងលោក ស៊ុន វណ្ណះ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ។

១៦- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ យឹន ស៊ីន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ។

១៧- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន យឹន ស៊ីន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

១៨- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ យឹន ស៊ីន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

១៩- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ។

២០- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ដន សម្បត្តិ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

២១- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

២២- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ។

២៣- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ឃុត ស្រីល័ក្ខ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

២៤- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

២៥- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ឡុង សុភាស់ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ។

២៦- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ឡុង សុភាស់ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

២៧- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ឡុង សុភាស់ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

២៨- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ឈឿង សំអាត ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១

២៩- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ឈឿង សំអាត ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

៣០- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ឈឿង សំអាត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

៣១- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ផៃ សុភារី ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១

៣២- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ផៃ សុភារី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

៣៣- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ផៃ សុភារី ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

៣៤- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ដន សំបូរ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១

៣៥- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ដន សំបូរ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ។

៣៦- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ដន សំបូរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ។

៣៧- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០

៣៨- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ទឹម ស៊ីឡាត់ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ។

៣៩- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១១ ។

៤០- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១

៤១- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ទឹម ស៊ីឡាត់ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ។

៤២- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១ ។

៤៣- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១១

៤៤- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ទឹម ស៊ីឡាត់ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១១ ។

៤៥- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ទឹម ស៊ីឡាត់ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១១ ។

៤៦- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ មាស សុខេន ។

៤៧- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន មាស សុខេន ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ។

៤៨- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ មាស សុខេន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ។

៤៩- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ មាស សុខេន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ។

៥០- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន មាស សុខេន ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ។

៥១- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ មាស សុខេន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១ ។

៥២- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ មាស សុខេន ។

៥៣- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន មាស សុខេន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ។

៥៤- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ មាស សុខេន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១១ ។

៥៥- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៥៦- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ឃុត ស្រីល័ក្ខ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ។

៥៧- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ។

៥៨- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ឃុត ស្រីល័ក្ខ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ។

៥៩- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១ ។

៦០- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ។

៦១- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១១ ។

៦២- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ឃុត ស្រីល័ក្ខ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១១ ។

៦៣- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ឃុត ស្រីល័ក្ខ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១១ ។

៦៤- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៦៥- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ដន សម្បត្តិ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ។

៦៦- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ។

៦៧- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១ ។

៦៨- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ដន សម្បត្តិ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ។

៦៩- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១១ ។

៧០- កិច្ចសន្យាការងារមានថេរវេលាកំណត់របស់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១១ ។

៧១- ពាក្យជូនដំណឹងកម្មករមានថេរៈវេលាកំណត់ជូន ដន សម្បត្តិ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១១ ។

៧២- កំណត់ហេតុផ្តាច់កិច្ចសន្យាការងារកម្មករមានថេរៈវេលាកំណត់ឈ្មោះ ដន សម្បត្តិ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១១ ។

៧៣- បញ្ជីឈ្មោះកម្មករផ្នែកឆែក ១ និង ២ ៕

៧៤- បញ្ជីឈ្មោះសហជីពដែលបានបង្កើតនៅក្នុងរោងចក្រ អឹម វេ (សាខាទី៤ ខេត្តកំពង់ឆ្នាំង) ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ ។

៧៥- លិខិតរបស់នាយកក្រុមហ៊ុន អឹម វេ កាត់ដេរអន្តជាតិ គោរពជូនឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ស្តីពីការសុំប្តឹងស្វែងរកជនមិនស្គាល់មុខដែលពាក់ព័ន្ធករណីលួចខោអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័រចំនួន ៣ ទូរ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ។

៧៦- លិខិតរបស់នាយកក្រុមហ៊ុន អឹម វេ កាត់ដេរអន្តជាតិ គោរពជូនឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ស្តីពីការសុំប្តឹងស្វែងរកជនមិនស្គាល់មុខដែលពាក់ព័ន្ធករណីលួចខោអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័រលេខ NYKU 8106169 ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ។

៧៧- លិខិតរបស់នាយកក្រុមហ៊ុន អឹម វេ កាត់ដេរអន្តជាតិ គោរពជូនឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ស្តីពីការសុំប្តឹងស្វែងរកជនមិនស្គាល់មុខដែលពាក់ព័ន្ធករណីលួចខោអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័របញ្ជូនចេញទៅប្រទេសអង់គ្លេស ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ។

៧៨- លិខិតរបស់នាយកក្រុមហ៊ុន អឹម វេ កាត់ដេរអន្តជាតិ គោរពជូនឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ស្តីពីការសុំប្តឹងស្វែងរកជនមិនស្គាល់មុខដែលពាក់ព័ន្ធករណីលួចខោអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័របញ្ជូនចេញទៅប្រទេសអង់គ្លេស ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ៣៨២/១១ សសកពក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការប្តឹងនាយកក្រុមហ៊ុន អឹម វេ សាខាទី៤ បញ្ឈប់ថ្នាក់ដឹកនាំសហជីព និងកម្មករ កម្មការិនីចំនួន ២០ នាក់ដោយគ្មានមូលហេតុ ។

២- ពាក្យបណ្តឹងតវ៉ានឹងដីកាសម្រេចរក្សាការពាររបស់កម្មករ កម្មការិនីបំរើការងារនៅក្រុមហ៊ុន អឹម វេ សាខាទី៤ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ ។

៣- លិខិតជូនដំណឹងធ្វើកូដកម្មរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ៣៨៥/១១ សសកពក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន អឹម វេ កំពង់ឆ្នាំង ។

៤- សៀវភៅការងារជនកម្ពុជារបស់ឈ្មោះ ទឹម ស៊ីឡាត់ ។

៥- សៀវភៅការងារជនកម្ពុជារបស់ឈ្មោះ ដន សម្បត្តិ ។

៦- សៀវភៅការងារជនកម្ពុជារបស់ឈ្មោះ ដន សំបូរ ។

៧- សៀវភៅការងារជនកម្ពុជារបស់ឈ្មោះ ឈឿន សំអាត។

៨- សៀវភៅការងារជនកម្ពុជារបស់ឈ្មោះ មាស សុខេន។

៩- សៀវភៅការងារជនកម្ពុជារបស់ឈ្មោះ ថៃ សុភារី ។

១០- លិខិតពឹងពាក់របស់កម្មករ កម្មការិនីបំរើការងារនៅរោងចក្រ អ៊ឹម វ៉េ ខេត្តកំពង់ឆ្នាំង គោរពជូនប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសំណើជួយអន្តរាគមន៍ និងការដោះស្រាយនូវការបញ្ឈប់កម្មករដោយគ្មានមូលហេតុ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ។

១១- បង្កាន់ដៃសុំចុះបញ្ជិការ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ។

១២- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ៣៩១/១១ សសកពក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ គោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការស្នើសុំសម្តេចអគ្គមហាសេនាបតីតេជោ មេត្តាសណ្តោសប្រណីជួយអន្តរាគមន៍ឱ្យនាយករោងចក្រ M&V 4 ទទួលយកកម្មករ កម្មការិនីដែលនិយោជកបញ្ឈប់ដោយខុសច្បាប់បានចូលបម្រើការងារជាធម្មតាវិញ ។

១៣- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាលេខ ៣៦៩/១១ សសកពក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន អ៊ឹម វ៉េ កំពង់ឆ្នាំង ស្តីពីការជូនដំណឹងអំពីមេដឹកនាំជាប់ឆ្នោតសហជីពសេរីកម្មករនៃរោងចក្រតម្បាញ អ៊ឹម វ៉េ កំពង់ឆ្នាំង ។

១៤- លិខិតរបស់សហជីពសេរីកម្មករនៃក្រុមហ៊ុនតម្បាញ អ៊ឹម និង វ៉េ កំពង់ឆ្នាំង គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើសុំចុះបញ្ជិកាសហជីពសេរីកម្មករនៃក្រុមហ៊ុនតម្បាញ អ៊ឹម និង វ៉េ កំពង់ឆ្នាំង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ។

១៥- កំណត់ហេតុបង្កើតសហជីពសេរីកម្មករនៃក្រុមហ៊ុនតម្បាញ អ៊ឹម និង វ៉េ កំពង់ឆ្នាំង ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១១ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អ៊ឹម និង វ៉េ កំពង់ឆ្នាំង លេខ ៥៩៣ កប/កឆ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អ៊ឹម និង វ៉េ កំពង់ឆ្នាំង ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៧៣៣ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៧៣៤ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែ តុលា ឆ្នាំ២០១១។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១១ ។

**អនុហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន អ៊ឹម វ៉េ សាខាទី៤ ខេត្តកំពង់ឆ្នាំ បានបើកដំណើរការនៅឆ្នាំ២០០១។ បច្ចុប្បន្ន ក្រុមហ៊ុនមាន ជួលកម្មករនិយោជិត សរុបប្រមាណ ៥០០០ នាក់។
- នៅក្នុងក្រុមហ៊ុននេះ មានសហជីពប្រចាំរោងចក្រចំនួន ៩ គឺសហជីពកម្មករកម្ពុជា សហជីពឧស្សាហកម្ម វាយនភ័ណ្ឌកាត់ដេរកម្ពុជា សហជីពប្រជាធិបតេយ្យជឿនលឿន សហជីពកម្មករនិយោជិត សហជីព សាមគ្គីភាព សហជីពជាតិកម្ពុជា សហជីពឧស្សាហកម្មកម្មករកម្ពុជា និងសហជីពសេរីកម្មករ។
- សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន ដែលជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ មិនទាន់បានទទួលការ ចុះបញ្ជិកានៅឡើយទេ គឺទើបតែទទួលបានបង្កាន់ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១។

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីព រួមទាំងសកម្មជនមួយចំនួនទៀត ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១**

- ថ្នាក់ដឹកនាំសហជីព រួមទាំងសកម្មជនសហជីពដែលទាមទារឱ្យក្រុមហ៊ុនទទួលយកចូលធ្វើការងារវិញនេះ គឺមានចំនួន ៩ នាក់ មានឈ្មោះ ដូចខាងក្រោម៖

| លរ | ឈ្មោះ | ភេទ | ផ្នែក | ថ្ងៃចូលធ្វើការដំបូង | កិច្ចសន្យាចុងក្រោយ |
|---|---|---|---|---|---|
| ១ | ទឹម ស៊ីឡាត់ | ស្រី | ផែកទី១ | ៣១/០៧/០៨ | ០១/០៨/១១ ដល់ ៣០/០៩/១១ |
| ២ | មាស សុខេន | ស្រី | ផែកទី១ | ២១/០៩/០៩ | ០១/០៨/១១ ដល់ ៣០/០៩/១១ |
| ៣ | ផៃ សុភារី | ស្រី | ផែកទី១ | ២០/០១/០៩ | ០១/០៨/១១ ដល់ ៣០/០៩/១១ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ឃុត ស្រីលក្ខិណា | ស្រី | ផ្នែកទី១ | ២០០៩ | ០១/០៨/១១ ដល់ ៣០/០៩/១១ |
| ៥ | ឈឿង សំអាត | ស្រី | ផ្នែកទី១ | ២០/០១/០៩ | ០១/០៨/១១ ដល់ ៣០/០៩/១១ |
| ៦ | ដន សម្បត្តិ | ស្រី | ផ្នែកទី១ | ២៩/១២/០៩ | ០១/០៨/១១ ដល់ ៣០/០៩/១១ |
| ៧ | ដន សំបូរ | ស្រី | ផ្នែកទី១ | ២៩/១២/០៩ | ០១/០៨/១១ ដល់ ៣០/០៩/១១ |
| ៨ | ឡុង សុភាស់ | ស្រី | ផ្នែកទី១ | មិនមាន | ០១/០៨/១១ ដល់ ៣០/០៩/១១ |
| ៩ | ឃីន ស៊ុម | ស្រី | ផ្នែកទី១ | មិនមាន | ០១/០៧/១១ ដល់ ៣០/០៩/១១ |

- កម្មករនិយោជិតទាំង ៩ នាក់នេះ ចូលធ្វើការដំបូងមានកិច្ចសន្យាការងារសាកល្បងរយៈពេល ២ ខែ បន្ទាប់មក ចុះកិច្ចសន្យាការងារមានថិរវេលាកំណត់រយៈពេល ៣ ខែម្តងៗ។ រៀងរាល់ចុងបញ្ចប់នៃកិច្ចសន្យា គឺមិនមានឈប់ទេ ទាល់តែដល់ខែទី១១ ទើបនិយោជកផ្តល់ប្រាក់បំណាច់កិច្ចសន្យាចំនួន៥ភាគរយ និងឱ្យកម្មករឈប់សម្រាកពី ៧ ថ្ងៃ ទៅ ១០ ថ្ងៃ ទើបបន្តកិច្ចសន្យាកម្មករនិយោជិតវិញ។
- ចំពោះកិច្ចសន្យាចុងក្រោយរបស់កម្មករនិយោជិតទាំង ៩ នាក់នេះ ដល់កាលកំណត់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១។ ក្រុមហ៊ុនបានជូនដំណឹង គឺហៅពួកគាត់មកប្រាប់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ថាក្រុមហ៊ុនមិនបន្តកិច្ចសន្យាសារជាថ្មីទេ ពីព្រោះក្រុមហ៊ុនអត់មានទំនិញ (ការងារ) ឱ្យធ្វើ ហើយនៅពេលក្រុមហ៊ុនមានការងារធ្វើវិញ ក្រុមហ៊ុននឹងហៅមកចូលធ្វើការវិញ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា កម្មករនិយោជិតធ្វើការនៅផ្នែកដែក ចែកចេញជាពីរ គឺផែក១ មានកម្មករនិយោជិតសរុប ចំនួន ៨៦ នាក់ និងផែក២ មានកម្មករនិយោជិតចំនួន ៣៩ នាក់។
- នៅផ្នែកផែក១ ក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ចំនួន ២៩ នាក់ ក្នុងនោះកម្មករនិយោជិតចំនួន ២០ នាក់ បានបើកប្រាក់ផ្តាច់កិច្ចសន្យារួចរាល់ហើយ លើកលែងតែពួកគាត់ទាំង ៩ នាក់ ដែលធ្វើការទាមទារចូលធ្វើការវិញនេះទេ ដែលមិនព្រមបើកប្រាក់ផ្តាច់នោះ។
- នៅផ្នែកផែក២ ក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ ចំនួន ១៤ នាក់ ហើយពួកគាត់ទាំងអស់ បានបើកប្រាក់ផ្តាច់កិចសន្យារួចអស់ហើយ។ ក្រុមហ៊ុនមិនបានរើសកម្មករនិយោជិតថ្មីជំនួសទេ។ ភាគីកម្មករនិយោជិតមិនជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីក្រុមហ៊ុនអះអាងថា ជាទូទៅ ក្នុងអំឡុងខែសីហា ខែកញ្ញា និងខែតុលា ក្រុមហ៊ុនមិនសូវមានការងារឱ្យកម្មករនិយោជិតធ្វើទេ ហើយក្រុមហ៊ុនតែងតែបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតណាដែលកិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ពួកគាត់ដល់កាលកំណត់ ដោយប្រាប់ថា រយៈពេល ៧ ថ្ងៃ ឬ ១០ ថ្ងៃ ទទួលយកឱ្យចូលធ្វើការវិញ។ ប៉ុន្តែដោយហេតុថា នៅក្នុងខែតុលា ឆ្នាំ២០១១ នេះ ក្រុមហ៊ុនមិនមានការបញ្ជាទិញ (មិនមានការងារឱ្យកម្មករនិយោជិតធ្វើ) ក្រុមហ៊ុនក៏បានសម្រេចបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតណាដែលកិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ពួកគាត់ដល់កាលកំណត់។ ហេតុ

នេះ ក្រុមហ៊ុនមិនអាចសន្យារយៈពេល ៧ ថ្ងៃ ឬ ១០ ថ្ងៃ ទទួលយកកម្មករនិយោជិតឱ្យចូលធ្វើការវិញទៀតទេ។

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កន្លងមក នៅពេលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតដែលកិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ពួកគាត់ដល់កាលកំណត់ ក្រុមហ៊ុនប្រាប់ឱ្យមកចូលធ្វើការវិញក្នុងរយៈពេល ៧ ថ្ងៃ ឬ ១០ ថ្ងៃ។ ប៉ុន្តែ នៅពេលនេះ ក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារពួកគាត់ទាំង ៩ នាក់នេះ ក្រុមហ៊ុនបែរជាប្រាប់ថា ក្រុមហ៊ុនមិនអាចកំណត់ថ្ងៃណាទេ គឺនៅពេលក្រុមហ៊ុនមានការងារឱ្យធ្វើទើបក្រុមហ៊ុនឱ្យចូលធ្វើការវិញ។ ដោយមូលហេតុនេះ ភាគីកម្មករនិយោជិត បានចោទប្រកាន់ថា ក្រុមហ៊ុនមានការរើសអើងសហជីព ពីព្រោះសហជីពបានរៀបចំបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១១ ដែលលោកស្រី ទឹម ស៊ីឡាត់ ជាប់ជាប្រធាន លោកស្រី មាស សុខខេន ជាប់ជាអនុប្រធាន និងលោកស្រី សូត្រ វណ្ណា ជាប់ជាលេខាធិការ។ ហើយសហជីពបានជូនដំណឹងទៅក្រុមហ៊ុន នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១។
- ភាគីក្រុមហ៊ុនបានទទួលស្គាល់ថា ក្រុមហ៊ុនបានទទួលការជូនដំណឹងថ្នាក់ដឹកនាំសហជីពនៅថ្ងៃនោះ ពិតប្រាកដមែន ប៉ុន្តែ ក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារជូនពួកគាត់ទាំង ៩ នាក់នេះ គឺមិនពាក់ពន្ធ័នឹងសហជីពទេ ។ មូលហេតុសំខាន់គឺ ក្រុមហ៊ុនមិនមានការបញ្ជាទិញ គឺអត់មានឥវ៉ាន់ឱ្យកម្មករនិយោជិតធ្វើតែម្តងជាពិសេសទៅទៀតនោះ ឥឡូវនេះ ក្រុមហ៊ុនកំពុងជួបទូវបញ្ហាបាត់អាវដាក់ក្នុងកុងទីន័រ ពីព្រោះអាវដែលដាក់នៅក្នុងកុងទីន័រ ផ្ញើទៅប្រទេសផ្សេងៗ ត្រូវបានចោរលួច ហើយក្រុមហ៊ុនបានដាក់ពាក្យបណ្តឹងទៅអគ្គស្នងការនគរបានជាតិ ដូចជា ពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ សុំប្តឹងស្វែងរកជនមិនស្គាល់មុខ ដែលពាក់ព័ន្ធនឹងករណីលួចអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័រ លេខ NYK ១១៨១០៦១៦៩ ដែលបញ្ជូនចេញទៅប្រទេសអង់គ្លេស កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ និងកុងទីន័រលេខ OOLU ៨២៨១១៤៩ ទៅប្រទេសអាល្លឺម៉ង់ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១១។ ពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ សុំប្តឹងស្វែងរកជនមិនស្គាល់មុខដែលពាក់ព័ន្ធនឹងករណីលួចអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័រ ចំនួន ៣ ទូរ ដែលទូរទី១ លេខ MRKU ២២០៣៩១០ ទូរទី២ លេខ NRKU ២២០២០៩៣ ដែលបញ្ជូនចេញទៅប្រទេសអង់គ្លេស កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១១ និងកុងទីន័រទី៣ លេខ NSKU ១៨៦២២៩០ បញ្ជូនចេញទៅប្រទេសអង់គ្លេស កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១។ ពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ សុំប្តឹងស្វែងរកជនមិនស្គាល់មុខដែលពាក់ព័ន្ធនឹងករណីលួចអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័រដែលបញ្ជូនចេញទៅប្រទេសអង់គ្លេសកាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ និងពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ សុំប្តឹងស្វែងរកជនមិនស្គាល់មុខដែលពាក់ព័ន្ធនឹងករណីលួចអាវរបស់ក្រុមហ៊ុនចេញពីកុងទីន័រ ដែលបញ្ជូនចេញទៅប្រទេសអង់គ្លេស កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១១ និងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ និងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១។ ហេតុនេះ ក្រុមហ៊ុនមិនអាចទទួលយកពួកគាត់ចូលធ្វើការវិញ ឬបន្តកិច្ចសន្យាការងារជាថ្មីតាមការទាមទារឡើយ ។

- ភាគីកម្មករនិយោជិតនៅតែរក្សាជំហរ ឱ្យក្រុមហ៊ុនទទួលយកពួកគាត់ទាំង ៩ នាក់ ឱ្យចូលធ្វើការវិញដដែល ។

**ហេតុផលនៃសេចក្តីសម្រេច:**

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីព រួមទាំងសកម្មជនមួយចំនួនទៀត ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១**

ក្នុងករណីនេះ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីព រួមទាំងសកម្មជនសរុបចំនួន ៩ នាក់ ឱ្យចូលធ្វើការវិញ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាករណីនេះ ដូចខាង ក្រោម:

មាត្រា ៧៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ត្រង់កថាខណ្ឌទី១ បានចែងថា *" កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលា ត្រូវផុតរលត់តាមធម្មតានៅពេលដល់កាលកំណត់ ។ ប៉ុន្តែកិច្ចសន្យានេះអាចរំលាយមុនកាលកំណត់តាមការព្រមព្រៀងរបស់ភាគីទាំងសងខាង ក្នុងលក្ខខណ្ឌដែលការព្រមព្រៀងនេះ ធ្វើឡើងជាលាយលក្ខណ៍អក្សរនៅចំពោះមុខអធិការការងារ និងចុះហត្ថលេខាដោយភាគីទាំងពីរនៃកិច្ចសន្យា" ។*

មាត្រា ៧៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ត្រង់កថាខ័ណ្ឌ ៦ បានចែងផងដែរថា *"នៅពេលបញ្ចប់កិច្ចសន្យា និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យានោះ ដែលសមាមាត្រនឹងប្រាក់ឈ្នួលផង សមាមាត្រនឹងថិរវេលានៃកិច្ចសន្យាការងារផង ហើយដែលចំនួនប្រាក់បំណាច់នេះមានកំណត់ក្នុងអនុសញ្ញារួម ។ បើគ្មានកំណត់ក្នុងអនុសញ្ញារួមទេ ប្រាក់បំណាច់នេះយ៉ាងតិចត្រូវស្មើប្រាំភាគរយនៃប្រាក់ឈ្នួល ដែលកម្មករនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យា " ។*

យោងតាមយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បកស្រាយថា កាតព្វកិច្ចនៃការបង់ប្រាក់បំណាច់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ដែលនិយោជកត្រូវបង់ គឺនៅពេលដែលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវបានបញ្ចប់ ហើយទំនាក់ទំនងការងាររវាងភាគីនិយោជក និងកម្មករនិយោជិតត្រូវបានកាត់ផ្តាច់ ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦០/០៦-ញូមេក ហ្គាមេន ហេតុផលចំណុចវិវាទទី៦, លេខ ៩៩/០៦-សៅធ៍ បាយ ហេតុផលចំណុចវិវាទទី៦, លេខ ៨៥/០៩-ណាន់ គ័ង ហេតុផលចំណុចវិវាទទី៤ និងលេខ ១២៤/០៩-ហ្វូគីស ហ្វូតវៀ ហេតុផលចំណុចវិវាទទី៣)* ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយពាក្យ"**អតីតភាព**" គឺមានន័យថា *"...អតីតភាពការងារ គឺជារយៈពេលនៃការធ្វើការងារជាបន្តបន្ទាប់ដែលផ្តល់សិទ្ធិ ឬបុព្វសិទ្ធិបន្ថែម ទៅឱ្យកម្មករនិយោជិតដោយផ្អែកទៅលើថិរវេលាបំរើការងារជាបន្តបន្ទាប់ទៅឱ្យនិយោជក ។... អតីតភាពនោះ នឹងឈប់បន្តនៅពេលដែលកម្មករនិយោជិតឈប់ធ្វើការងារឱ្យសហគ្រាសនោះប៉ុណ្ណោះ..."* ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៨/០៥-ហ្គោលលើដា, លេខ ៧៥/០៥-ហ្វូចូន ហ្គាមេន, លេខ ១៧/១០-ហ្សុងចិច ហ្គាមេន ហេតុផលចំណុចវិវាទទី៣, លេខ ៦០/១០-គីនតាយ ហេតុផលចំណុចវិវាទទី២ និងលេខ ១០១/១០-ត្រីប៊ូស អ៊ិនធើណេសិនណល ហេតុផលចំណុចវិវាទទី២)* ។

យោងតាមការបកស្រាយខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អតីតភាពការងាររបស់កម្មករនិយោជិត ត្រូវបានបន្តគិតទៅតាមរយៈពេលដែលកម្មករនិយោជិតធ្វើការជាក់ស្តែងនៅក្នុងក្រុមហ៊ុន ដរាបណាកម្មករនិយោជិតនោះមិនទាន់ឈប់ធ្វើការឱ្យសហគ្រាស ឬក្រុមហ៊ុននោះនៅឡើយទេ។ ក្នុងករណីដែលកម្មករនិយោជិតត្រូវបានឈប់ធ្វើការ និងលែងមានទំនាក់ទំនងការងារជាក់ស្តែងជាមួយនិយោជកមួយរយៈ (មួយ ឬ ពីរសប្តាហ៍) នោះអតីតភាពការងារក៏ត្រូវបានបញ្ចប់។

នៅក្នុងសំណុំរឿងនេះ ទំនាក់ទំនងការងាររវាងភាគីនិយោជក និងកម្មករនិយោជិតត្រូវបានកាត់ផ្តាច់ ដោយនិយោជកបានធ្វើការទូទាត់ប្រាក់បំណាច់កិច្ចសន្យាការងារចំនួន ៥ ភាគរយ និងបំពេញកាតព្វកិច្ចបង់ប្រាក់បន្ទាប់បន្សំផ្សេងៗទៀត ដែលមានចែងក្នុងច្បាប់ស្តីពីការងារ។ ក្រោយពីបញ្ចប់កិច្ចសន្យាការងារតាមកាលកំណត់ កម្មករនិយោជិតបានស្ថិតនៅក្រៅរោងចក្រដោយមិនមានកាតព្វកិច្ចត្រូវរង់ចាំ ឬត្រូវផ្តល់សេវាជូននិយោជកឡើយ ដោយកម្មករនិយោជិតបានឈប់មួយ ឬពីរសប្តាហ៍មកហើយ។

ហេតុនេះ អតីតភាពរបស់កម្មករនិយោជិត គឺមាននៅកិច្ចសន្យាចុងក្រោយរបស់ពួកគាត់ដែលមានរយៈពេលពីរខែចំពោះកម្មករនិយោជិត ៨ នាក់ និងបីខែចំពោះកម្មករនិយោជិត ឃីន ស៊ីម។

យោងតាមមាត្រា ៧៣ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ កថាខណ្ឌទី១ ចែងថា *"ប្រសិនបើកិច្ចសន្យាមានកំណត់ថិរវេលាលើសពីប្រាំមួយខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុនចំនួនដប់ថ្ងៃ អំពីការផុតរលត់នៃកិច្ចសន្យា ឬការមិនបន្តឡើងវិញនៃកិច្ចសន្យា..."*។ យោងតាមមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំពោះកិច្ចសន្យាដែលមានកំណត់ថិរវេលាលើសពីប្រាំមួយខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុនចំនួន១០ថ្ងៃអំពីការផុតរលត់នៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ឬការមិនបន្តឡើងវិញនៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានោះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ ក្រុមហ៊ុនបានជូនដំណឹងទៅពួកគាត់ទាំង ៩ នាក់ ថា ក្រុមហ៊ុននឹងបញ្ចប់កិច្ចសន្យាការងាររបស់ពួកគាត់នៅថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០១១ ពោលគឺ ១១ ថ្ងៃ មុនកិច្ចសន្យាដល់កាលកំណត់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំពោះកិច្ចសន្យាការងារមានថិរវេលាកំណត់មិនលើសពី ៦ ខែ មិនតម្រូវឱ្យនិយោជកជូនដំណឹងអំពីការមិនបន្តកិច្ចសន្យាសារជាថ្មីនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុនបានអនុវត្តការជូនដំណឹងនេះ ប្រសើរជាងច្បាប់តម្រូវឱ្យ។

ប៉ុន្តែ ដោយសារពួកគាត់ទាំង ៩ នាក់ ជាថ្នាក់ដឹកនាំសហជីព និងសកម្មជនសហជីព ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើពួកគាត់បានការការពារពីការផុតរលត់នៃកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាដែលតម្រូវឱ្យនិយោជក ត្រូវសុំការអនុញ្ញាតបញ្ចប់កិច្ចសន្យាការងារផុតរលត់នេះពីអធិការការងារ ដែរ ឬទេ?

យោងតាមមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬ រាល់ការបញ្ឈប់ជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ..."*។

ប្រការ៤ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាចែងថា “ *...ការការពារនេះ ត្រូវបានផ្តល់ឱ្យថ្នាក់ដឹកនាំសហជីព ០៣ រូប ក្នុងលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ ...*” ។

តាមន័យនៃមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ និងប្រការ៤ នៃប្រកាសលេខ ៣០៥ សកបយ ខាងលើ ការការពារពិសេសចំពោះថ្នាក់ដឹកនាំសហជីពទាំង០៣រូប រួមមានប្រធាន អនុប្រធាន និងលេខាសហជីព កើតមានតែចំពោះករណីបញ្ឈប់ពីការងារប៉ុណ្ណោះ ដែលត្រូវតម្រូវឱ្យនិយោជកសុំការអនុញ្ញាតពីអធិការការងារ ។

ប៉ុន្តែចំពោះករណីដល់កាលកំណត់ ឬផុតរលត់នៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់ថ្នាក់ដឹកនាំសហជីព មិនមានមាត្រាច្បាប់ណាដែលតម្រូវឱ្យនិយោជកត្រូវសុំការអនុញ្ញាតពីអធិការការងារទេ *(សូមមើលសេចក្តីបង្គាប់ អាជ្ញាកណ្តាលលេខ ១០/០៩-ញូវ៉ាយជី ខេមបូឌា ហេតុផលចំណុចវិវាទទី១ និងទី២ និងលេខ ១៥៥/០៩-យូអេស អេ ហេតុផលចំណុចវិវាទទី៨)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ឃើញដូចក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺនិយោជកមិនត្រូវបានតម្រូវឱ្យសុំការអនុញ្ញាតពីអធិការការងារទេ ក្នុងការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់ថ្នាក់ដឹកនាំសហជីព ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកមិនបានសុំការអនុញ្ញាតពីអធិការងារ អំពីការបញ្ចប់កិច្ចសន្យាពួកគាត់ទាំង ៩ នាក់ ទេ ដោយសារការផុតរលត់នៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ។ ការមិនបានសុំការអនុញ្ញាតពីអធិការងារ អំពីការបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលានេះ ក្រុមហ៊ុនមិនបានអនុវត្តខុសពីនីតិវិធីច្បាប់ទេ ។

ចំពោះការលើកឡើងពីការរើសអើងសហជីព ច្បាប់ស្តីពីការងារបានចែងថា៖

មាត្រា ១២ នៃច្បាប់ស្តីពីការងារបានចែងថា “ *..... គ្មាននិយោជកណាម្នាក់អាចយកបញ្ហាការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីសម្រេចអំពី.......ការជួល ការកំណត់ និងការបែងចែកការងារ.....*” ។

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា “ *ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូបមិនឱ្យយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសំរេចក្នុងការ... បែងចែកការងារ....*” ។

តាមខ្លឹមសារមាត្រា ១២ និងមាត្រា ២៧៩ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកមិនត្រូវយកមូលហេតុនៃការចូលជាសមាជិកសហជីពរបស់កម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីពរបស់កម្មករនិយោជិតជាមូលដ្ឋាន នៅក្នុងការជួលកម្មករនិយោជិតនោះទេ ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៨/០៧-ដេហ្វាង ហេតុផលចំណុចវិវាទទី៣ និងលេខ ១២៣/០៧-អ៊ី ហ្គាមេទ ហេតុផលចំណុចវិវាទទី១)* ។

ប៉ុន្តែ ជាទូទៅ នៅក្នុងករណីការទាមទារដែលពាក់ព័ន្ធនឹងការរើសអើងសហជីព ភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាងថា ភាគីនិយោជកមានការរើសអើងសហជីព *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៦/០៩-សាន់តិច ហេតុផលនៃចំណុចវិវាទទី២ និងលេខ ៦១/០៩-ស៊ីនទ្រី ហេតុផលនៃចំណុចវិវាទទី១)* ។

យោងតាមអង្គហេតុ ភាគីក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាជូនដល់ពួកគាត់ទាំង ៩ នាក់ គឺដោយសារតែនៅក្នុងក្រុមហ៊ុនមិនមានការងារឱ្យពួកគាត់ធ្វើទៀត ហើយកិច្ចសន្យាការងាររបស់ពួកគាត់ដល់កាលកំណត់ត្រូវផុតរលត់ផងដែរ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រៅពីការបញ្ចប់កិច្ចសន្យារបស់កម្មករនិយោជិតទាំង ០៩ នាក់ និយោជកក៏បញ្ចប់កិច្ចសន្យារបស់កម្មករនិយោជិតដទៃដែរ ដូចជា កម្មករនិយោជិតធ្វើការនៅផ្នែកឆែក១ ចំនួន ២៩ នាក់ ក្នុងនោះកម្មករនិយោជិតចំនួន ២០ នាក់ បានបើកប្រាក់ផ្តាច់កិច្ចសន្យារួចរាល់ហើយ លើកលែងតែពួកគាត់ទាំង ០៩ នាក់ ដែលធ្វើការទាមទារចូលធ្វើការវិញនេះទេ ដែលមិនព្រមបើកប្រាក់ផ្តាច់នោះ ។ នៅផ្នែកឆែក២ ចំនួន ១៤ នាក់ ហើយពួកគាត់ទាំងអស់បានបើកប្រាក់ផ្តាច់កិច្ចសន្យារួចអស់ហើយ ហើយក្រុមហ៊ុនមិនបានរើសកម្មករនិយោជិតថ្មីជំនួសពួកគាត់ទេ ។ ម្យ៉ាងទៀត ចំពោះការលើកឡើងរបស់និយោជកថា ការបាត់ឥវ៉ាន់របស់ក្រុមហ៊ុន ជាហេតុបណ្តាលឱ្យក្រុមហ៊ុនមិនអាចទទួលបានការបញ្ជាទិញបន្ថែម ភាគីកម្មករនិយោជិតក៏មិនបានជំទាស់ទៅនឹងឯកសារ និងភស្តុតាងនានា ដែលភាគីក្រុមហ៊ុនដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចជា ឥវ៉ាន់ (អាវ) ដែលដាក់នៅក្នុងកុងទីន័រដែលក្រុមហ៊ុនបានផ្ញើទៅប្រទេសផ្សេងៗ ត្រូវបានចោរលួច ហើយក្រុមហ៊ុនក៏បានដាក់ពាក្យបណ្តឹងជាច្រើនទៅអគ្គស្នងការនគរបាលជាតិផងដែរ ។

ចំណែក ភាគីកម្មករនិយោជិតមិនបានបង្ហាញភស្តុតាងគ្រប់គ្រាន់ ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចសន្និដ្ឋានបានថា និយោជកមានការរើសអើងសហជីពនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា ការបញ្ចប់កិច្ចសន្យាការងាររបស់ពួកគាត់ទាំង ៩ នាក់នេះ មានការរើសអើងសហជីពទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកទទួលយកពួកគាត់ទាំង ០៩ នាក់ ចូលធ្វើការវិញ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖

ចំណុចវិវាទទី១ ៖ បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកទទួលយកពួកគាត់ទាំង ០៩ នាក់ ចូលធ្វើការវិញ ។

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០។*

២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖ គ្មាន

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------